**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**
**Kingdom of Cambodia**
**Nation Religion King**

**ក្រសួងរ៉ែ និងថាមពល**
**Ministry of Mines and Energy**
លេខ: ០២២៥.២៤.ឋវប.ប្រក

# ប្រកាស
## ស្តីពី
## ការដាក់ឱ្យអនុវត្តគោលការណ៍ណែនាំស្តីពីសុវត្ថិភាពសម្រាប់ដំណើរការ ស្ថានីយប្រេងឥន្ធនៈ ស្ថានីយឧស្ម័នឥន្ធនៈ និងស្ថានីយរួមប្រេងឥន្ធនៈនិងឧស្ម័នឥន្ធនៈ

## រដ្ឋមន្ត្រីក្រសួងរ៉ែ និងថាមពល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨២៣/១៩៨១ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០២៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២១៣/០១៧ ចុះថ្ងៃទី០៩ ខែធ្នូ ឆ្នាំ២០១៣ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងរ៉ែ និងថាមពល
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៧១៩/០០៦ ចុះថ្ងៃទី១២ ខែកក្កដា ឆ្នាំ២០១៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងប្រេងកាតនិងផលិតផលប្រេងកាត
- បានឃើញអនុក្រឹត្យលេខ១៣៧ អនក្រ.បក ចុះថ្ងៃទី៣១ ខែតុលា ឆ្នាំ២០១៨ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងរ៉ែ និងថាមពល
- បានឃើញអនុក្រឹត្យលេខ១៧៧ អនក្រ.បក ចុះថ្ងៃទី១ ខែកញ្ញា ឆ្នាំ២០២២ ស្តីពីការអនុវត្តច្បាប់ស្តីពីការគ្រប់គ្រងប្រេងកាតនិងផលិតផលប្រេងកាត ផ្នែកដោនស្ទ្រីម
- បានឃើញប្រកាសលេខ០២១៤ រថ.នក.ប្រក ចុះថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០២២ ស្តីពីការធ្វើប្រតិភូកម្មមុខងារក្នុងការផ្តល់សេវារដ្ឋបាលពាក់ព័ន្ធនឹងការផ្តល់លិខិតអនុញ្ញាតសម្រាប់សកម្មភាពផ្នែកដោនស្ទ្រីម ទៅឱ្យរដ្ឋបាលរាជធានី ខេត្ត របស់ក្រសួងរ៉ែ និងថាមពល
- បានឃើញប្រកាសលេខ០០៩៩ រថ.អគទទ.ប្រក ចុះថ្ងៃទី២៧ ខែកុម្ភៈ ឆ្នាំ២០២៣ ស្តីពីការកែសម្រួលប្រការ១០ នៃប្រកាសលេខ០២១៤ រថ.នក.ប្រក ចុះថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០២២ ស្តីពីការធ្វើប្រតិភូកម្មមុខងារក្នុងការផ្តល់សេវារដ្ឋបាលពាក់ព័ន្ធនឹងការផ្តល់លិខិតអនុញ្ញាតសម្រាប់សកម្មភាពផ្នែកដោនស្ទ្រីម ទៅឱ្យរដ្ឋបាលរាជធានី ខេត្ត របស់ក្រសួងរ៉ែ និងថាមពល



លេខ ១ មហាវិថីព្រះនរោត្តម សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ ទូរស័ព្ទ (៨៥៥) ២៣ ២១៩ ៥៧៤
#1, Preah Norodom Blvd, Sangkat Wat Phnom, Khan Daun Penh, Phnom Penh. Tel: (855) 23 219 574 www.mme.gov.kh info@mme.gov.kh

- បានឃើញប្រកាសលេខ០១៨៩ រថ.បវប.ប្រក ចុះថ្ងៃទី២៣ ខែកក្កដា ឆ្នាំ២០២៤ ស្ដីពីលក្ខខណ្ឌ និងនីតិវិធីនៃការផ្ដល់ វិញ្ញាបនបត្របញ្ជាក់បច្ចេកទេសសុវត្ថិភាព និងអាជ្ញាបណ្ណសម្រាប់សកម្មភាពផ្នែកដោនស្រ្ទីម របស់ក្រសួងរ៉ែ និងថាមពល
- បានឃើញប្រកាសលេខ០១៩០ រថ.បវប.ប្រក ចុះថ្ងៃទី២៣ ខែកក្កដា ឆ្នាំ២០២៤ ស្ដីពីបទប្បញ្ញត្តិបច្ចេកទេសសុវត្ថិភាពសម្រាប់ការរៀបចំស្ថានីយប្រេងឥន្ធនៈ ស្ថានីយឧស្ម័នឥន្ធនៈ និងស្ថានីយរួមប្រេងឥន្ធនៈនិងឧស្ម័នឥន្ធនៈ របស់ក្រសួងរ៉ែ និងថាមពល
- យោងតាមតម្រូវការចាំបាច់របស់ក្រសួងរ៉ែ និងថាមពល

**សម្រេច**

**ប្រការ១ .-**

ត្រូវបានដាក់ឱ្យអនុវត្តគោលការណ៍ណែនាំស្ដីពីសុវត្ថិភាពសម្រាប់ដំណើរការស្ថានីយប្រេងឥន្ធនៈ ស្ថានីយឧស្ម័នឥន្ធនៈ និងស្ថានីយរួមប្រេងឥន្ធនៈនិងឧស្ម័នឥន្ធនៈ ដើម្បីបង្ការអគ្គិភ័យដែលអាចកើតមានឡើងជាយថាហេតុ និងធានាសុវត្ថិភាពដល់ស្ថានីយ បុគ្គលិក អតិថិជន និងអ្នកជិតខាង។

**ប្រការ២ .-**

គោលការណ៍ណែនាំស្ដីពីសុវត្ថិភាពសម្រាប់ដំណើរការស្ថានីយប្រេងឥន្ធនៈ ស្ថានីយឧស្ម័នឥន្ធនៈ និងស្ថានីយរួមប្រេងឥន្ធនៈនិងឧស្ម័នឥន្ធនៈ មានខ្លឹមសារជាឧបសម្ព័ន្ធនៃប្រកាសនេះ។

**ប្រការ៣ .-**

បទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយនឹងប្រកាសនេះ ត្រូវទុកជានិរាករណ៍។

**ប្រការ៤ .-**

នាយកខុទ្ទកាល័យ អគ្គនាយកនៃអគ្គនាយកដ្ឋានកិច្ចការទូទៅ អគ្គនាយកនៃអគ្គនាយកដ្ឋានប្រេងកាត អគ្គាធិការនៃអគ្គាធិការដ្ឋាន ប្រធាននាយកដ្ឋានសវនកម្ម និងប្រធានមន្ទីររ៉ែ និងថាមពលរាជធានី ខេត្ត ត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះតាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃសុក្រ ១១កើត ខែភទ្របទ ឆ្នាំរោង ឆស័ក ព.ស.២៥៦៨

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១៣ ខែកញ្ញា ឆ្នាំ២០២៤

**រដ្ឋមន្ត្រីក្រសួងរ៉ែ និងថាមពល**

**កែវ រតនៈ**

**កន្លែងទទួលៈ**

- ទីស្ដីការគណៈរដ្ឋមន្ត្រី
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ខុទ្ទកាល័យសម្ដេចមហាបវរធិបតីនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្ដមឧបនាយករដ្ឋមន្ត្រី
- រដ្ឋបាលរាជធានី ខេត្ត
- ដូចប្រការ៤
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

**ឧបសម្ព័ន្ធនៃប្រកាសលេខ ០២២៥ រ៉ៈបវប.ប្រក ចុះថ្ងៃទី ១៣ ខែ កញ្ញា ឆ្នាំ២០២៤ ស្តីពី**
**ការដាក់ឱ្យអនុវត្តគោលការណ៍ណែនាំស្តីពីសុវត្ថិភាពសម្រាប់ដំណើរការ**
**ស្ថានីយប្រេងឥន្ធនៈ ស្ថានីយឧស្ម័នឥន្ធនៈ និងស្ថានីយរួមប្រេងឥន្ធនៈនិងឧស្ម័នឥន្ធនៈ**

# គោលការណ៍ណែនាំ
# ស្តីពី
# សុវត្ថិភាពសម្រាប់ដំណើរការ
# ស្ថានីយប្រេងឥន្ធនៈ ស្ថានីយឧស្ម័នឥន្ធនៈ និងស្ថានីយរួមប្រេងឥន្ធនៈនិងឧស្ម័នឥន្ធនៈ

# សេចក្ដីផ្ដើម

បច្ចុប្បន្ននេះ តម្រូវការប្រើប្រាស់ប្រេងឥន្ធនៈនិងឧស្ម័នឥន្ធនៈនៅព្រះរាជាណាចក្រកម្ពុជាបាននិងកំពុងមានការកើនឡើងស្របជាមួយនឹងការរីកចម្រើនគ្រប់វិស័យនៃសេដ្ឋកិច្ចជាតិ។ ទន្ទឹមនឹងនេះ ការនាំចូល សន្និធិ ការដឹកជញ្ជូន និងការលក់ចែកចាយប្រេងឥន្ធនៈនិងឧស្ម័នឥន្ធនៈ សម្រាប់បម្រើសេចក្ដីត្រូវការរបស់អ្នកប្រើប្រាស់ក្នុងរាជធានីភ្នំពេញ និងតាមបណ្ដាខេត្ត ក៏មានការកើនឡើងច្រើនផងដែរ។ ជាមួយគ្នានេះ ក្រសួងរ៉ែ និងថាមពលសង្កេតឃើញថា ឧបទ្ទវហេតុនៃគ្រោះអគ្គិភ័យដែលបណ្ដាលមកពីការផ្ទុះ និងការឆាបឆេះប្រេងឥន្ធនៈ និងឧស្ម័នឥន្ធនៈតាមស្ថានីយប្រេងឥន្ធនៈ ស្ថានីយឧស្ម័នឥន្ធនៈ និងស្ថានីយរួមប្រេងឥន្ធនៈនិងឧស្ម័នឥន្ធនៈ (ស្ថានីយ) ក៏បានកើតឡើងជាបន្តបន្ទាប់ដែលធ្វើឱ្យមានការខូចខាតទ្រព្យសម្បត្តិ រងរបួស និងបាត់បង់អាយុជីវិតថែមទៀតផង។

ក្រសួងរ៉ែ និងថាមពលរៀបចំ **"គោលការណ៍ណែនាំស្ដីពីសុវត្ថិភាពសម្រាប់ដំណើរការស្ថានីយប្រេងឥន្ធនៈ ស្ថានីយឧស្ម័នឥន្ធនៈ និងស្ថានីយរួមប្រេងឥន្ធនៈនិងឧស្ម័នឥន្ធនៈ"** នេះឡើង ជាយន្តការបន្ថែមលើបទប្បញ្ញត្តិបច្ចេកទេសសុវត្ថិភាពសម្រាប់ការរៀបចំស្ថានីយដែលបានដាក់ចេញ ដើម្បីបង្ការអគ្គិភ័យដែលអាចកើតមានឡើងជាយថាហេតុ និងធានាសុវត្ថិភាពដល់ស្ថានីយ បុគ្គលិក អតិថិជន និងអ្នកជិតខាង។

គោលការណ៍ណែនាំនេះ មានខ្លឹមសារដូចខាងក្រោម៖

## ១- ការរៀបចំរចនាសម្ព័ន្ធគ្រប់គ្រងស្ថានីយ

ម្ចាស់ស្ថានីយត្រូវរៀបចំឱ្យបានច្បាស់លាស់អំពីរចនាសម្ព័ន្ធគ្រប់គ្រងស្ថានីយ តួនាទី និងការទទួលខុសត្រូវរបស់ផ្នែកនីមួយៗ។

រចនាសម្ព័ន្ធគ្រប់គ្រងស្ថានីយ អាចមានប្រធានគ្រប់គ្រង និង/ឬអនុប្រធានគ្រប់គ្រង និង/ឬអ្នកគ្រប់គ្រងសុវត្ថិភាព និងបុគ្គលិក ទៅតាមទំហំនៃស្ថានីយ។

ប្រធានគ្រប់គ្រង ត្រូវទទួលខុសត្រូវទាំងអស់ក្នុងការធានាសុវត្ថិភាពក្នុងស្ថានីយ និងត្រូវមានវិញ្ញាបនបត្របញ្ជាក់ការសិក្សា តាមរយៈការចូលរួមវគ្គបណ្ដុះបណ្ដាល ឬសិក្ខាសាលាដែលផ្ដល់ដោយក្រសួងរ៉ែ និងថាមពល ឬស្ថាប័នដែលទទួលស្គាល់ដោយក្រសួងរ៉ែ និងថាមពល។

## ២- ការអប់រំបុគ្គលិក

ប្រធានគ្រប់គ្រង អនុប្រធានគ្រប់គ្រង ឬអ្នកគ្រប់គ្រងសុវត្ថិភាពស្ថានីយត្រូវអប់រំបុគ្គលិកជាប្រចាំ ជាពិសេសបុគ្គលិកចូលថ្មីនូវចំណេះដឹងជាមូលដ្ឋានរួមមាន៖

២.១- លក្ខណៈ និងគ្រោះថ្នាក់នៃប្រេងសាំង ប្រេងម៉ាស៊ូត និងឧស្ម័នអិលភីជី

ក- ប្រេងសាំង

- អាចភាយជាចំហាយចេញនៅសីតុណ្ហភាព ៤០ អង្សាសេក្រោមសូន្យ (- 40 $^0$C)
- ចំហាយប្រេងសាំងធ្ងន់ជាងខ្យល់ ហើយប្រមូលផ្ដុំគ្នានៅតាមកន្លែងទាបៗ និង
- ចំហាយអាចឆាបឆេះបានបើមានប្រភពបញ្ឆេះ ឬបាតុភូតអេឡិចត្រូស្ដាទិកកើតឡើងនៅក្បែរ។

ខ- ប្រេងម៉ាស៊ូត

- អាចភាយជាចំហាយចេញនៅសីតុណ្ហភាព ៤៥ អង្សាសេ (45 $^0$C)

- ចំហាយអាចឆាបឆេះបានបើមានប្រភពបញ្ឆេះ ឬបាតុភូតអេឡិចត្រូស្តាទិកកើតឡើងនៅក្បែរវា និង
- ប្រេងម៉ាស៊ូតឆាបឆេះយឺតជាងប្រេងសាំង។

គ- ឧស្ម័នអិលភីជី

- មានសមាសធាតុប្រូប៉ាន និងប៊ុយតាន ហើយគ្មានក្លិន គ្មានពណ៌ និងធ្ងន់ជាងខ្យល់
- មានសភាពជាឧស្ម័ននៅសីតុណ្ហភាពធម្មតា ប៉ុន្តែមានសភាពរាវនៅពេលស្ថិតក្នុងកំប៉ុង ដប ធុងស៊ីទែនយានយន្ត ពោងស្តុក និងបំពង់បង្ហូរ
- ទម្ងន់ ១ គីឡូក្រាមនៃឧស្ម័នអិលភីជី មានចំណុះប្រហែល ២លីត្រ ក្នុងសភាពរាវ និងមានចំណុះប្រហែល ៥០០លីត្រ ក្នុងសភាពជាឧស្ម័ន
- អាចកំណត់ការលេចធ្លាយបានដោយសារក្លិនដែលត្រូវបានលាយបញ្ចូលពេលផលិត
- ល្បាយក្នុងខ្យល់ដែលមានកំហាប់ចាប់ពី ២% ទៅដល់ ១០% ឧស្ម័នអិលភីជីនឹងផ្ទុះឆេះបើមានប្រភពបញ្ឆេះ ឬបាតុភូតអេឡិចត្រូស្តាទិកកើតឡើងនៅក្បែរវា និង
- ពេលធ្លាយចេញក្នុងបរិមាណច្រើន ឧស្ម័នអិលភីជីនឹងឆាបឆេះយ៉ាងរហ័ស និងបណ្តាលឱ្យផ្ទុះយ៉ាងខ្លាំង បើមានប្រភពបញ្ឆេះ ឬបាតុភូតអេឡិចត្រូស្តាទិកកើតឡើងនៅក្បែរវា។

២.២- របៀបប្រើឧបករណ៍ពន្លត់អគ្គិភ័យៈ ត្រូវអនុវត្តតាមការកំណត់របស់អង្គភាពនគរបាលបង្ការពន្លត់អគ្គិភ័យ និងសង្គ្រោះ។

## ៣- នីតិវិធីប្រតិបត្តិការសុវត្ថិភាព

ប្រធានគ្រប់គ្រង អនុប្រធានគ្រប់គ្រង អ្នកគ្រប់គ្រងសុវត្ថិភាព និង/ឬបុគ្គលិកត្រូវអនុវត្តនីតិវិធីប្រតិបត្តិការសុវត្ថិភាពឱ្យបានហ្មត់ចត់ដូចខាងក្រោមៈ

៣.១- ការត្រួតពិនិត្យប្រចាំថ្ងៃ មុនពេលចាប់ផ្តើមការងារ

រៀងរាល់ថ្ងៃ មុនពេលចាប់ផ្តើមការងារប្រធានគ្រប់គ្រង អនុប្រធានគ្រប់គ្រង ឬអ្នកគ្រប់គ្រងសុវត្ថិភាពស្ថានីយ ត្រូវធ្វើការត្រួតពិនិត្យការងារដូចខាងក្រោម៖

- កត់ត្រាបរិមាណប្រេងឥន្ធនៈ និងឧស្ម័នឥន្ធនៈដែលមាននៅក្នុងពោងនីមួយៗ
- ពិនិត្យភាពមិនប្រក្រតីនៃម៉ូទ័របូម ម៉ូទ័ររុញសម្ពាធ ដូចជាការលេចជ្រាប សំឡេងមិនប្រក្រតី និងប៊ូឡុងរលុង ជាដើម
- ពិនិត្យការលេចជ្រាបប្រេងឥន្ធនៈពីទុយយោ និងចំពួយចាក់ប្រេងឥន្ធនៈ
- មិនឱ្យមានវត្ថុងាយឆេះដូចជាប្រេងសាំងដប ប៊ីដុងជ័រមានផ្ទុកប្រេងឥន្ធនៈ ធុងនិងកំប៉ុងឧស្ម័នឥន្ធនៈជាដើម នៅក្បែរពោង កបំពង់ទទួល និងទូចាក់ប្រេងឥន្ធនៈ ឬឧស្ម័នឥន្ធនៈ
- មិនឱ្យមានប្រភពបញ្ឆេះដូចជាចង្ក្រាន រានទេវតា ព្រីភ្លើង បារ៉ែតភ្លើង ទូភ្លាសេ ទូទឹកកកជាដើម នៅក្បែរពោង កបំពង់ទទួល និងទូចាក់ប្រេងឥន្ធនៈ ឬឧស្ម័នឥន្ធនៈ
- ពិនិត្យនិងទុកដាក់បំពង់ពន្លត់អគ្គិភ័យឱ្យបានត្រឹមត្រូវនិងមានចំនួនគ្រប់គ្រាន់សម្រាប់ប្រើប្រាស់
- ហាមបុគ្គលិកមិនឱ្យប្រើដែកកេះ និងស្បែកជើងដែលបាតមានដែក
- ករណីស្ថានីយឧស្ម័នឥន្ធនៈ និងស្ថានីយរួមប្រេងឥន្ធនៈនិងឧស្ម័នឥន្ធនៈ ត្រូវពិនិត្យភាពខូចខាតនៃផ្ទៃពោងឧស្ម័នឥន្ធនៈ ជើងទម្រពោង នាឡិកាសម្ពាធ នាឡិកាកម្រិតចំណុះ ឧបករណ៍វាស់សីតុណ្ហភាព ប្រព័ន្ធបំពង់បង្ហូរ

- បើរកឃើញថាមានឧបករណ៍ប្រេងឥន្ធនៈ ឬឧស្ម័នឥន្ធនៈណាមួយមានការខូចត្រូវធ្វើការផ្លាស់ប្តូរ ឬជួសជុលឧបករណ៍នោះជាបន្ទាន់ និង
- ត្រូវធ្វើការត្រួតពិនិត្យលើឧបករណ៍ក្នុងទ្រង់ទ្រាយធំពីអ្នកជំនាញបន្ទាប់ពីប្រើប្រាស់ក្នុងរយៈពេលយូរ។

៣.២- ការផ្តល់សេវាជូនអតិថិជន

បុគ្គលិកស្ថានីយត្រូវផ្តល់សេវាជូនអតិថិជនឱ្យបានល្អដូចខាងក្រោម៖

ក- ពេលយានយន្តអតិថិជនចូល៖

- ត្រូវណែនាំអតិថិជនឱ្យបើកយានយន្តទៅកាន់ទីតាំងចាក់ប្រេងឥន្ធនៈ ឬឧស្ម័នឥន្ធនៈឱ្យបានត្រឹមត្រូវ
- កុំឈរនៅខាងមុខ ឬពីក្រោយយានយន្ត ដើម្បីជៀសវាងគ្រោះថ្នាក់
- ស្នើសុំពន្លត់ម៉ាស៊ីន និងដាក់ហ្វ្រាំងចតយានយន្ត និង
- ត្រូវប្រាកដថាពុំមានការជក់បារីនៅក្នុងយានយន្ត។

ខ- ពេលចាក់ប្រេងឥន្ធនៈ ឬឧស្ម័នឥន្ធនៈ៖

- ហាមអតិថិជនជក់បារី
- ហាមប្រើទូរស័ព្ទ
- ត្រូវរំសាយបាតុភូតអេឡិចត្រូស្តាទិក
- បើកគម្របធុងប្រេងឥន្ធនៈ ឬឧស្ម័នឥន្ធនៈយានយន្ត
- ត្រូវបញ្ជាក់ពីប្រភេទ និងបរិមាណប្រេងឥន្ធនៈ ឬឧស្ម័នឥន្ធនៈដែលអតិថិជនត្រូវចាក់
- កំណត់បរិមាណប្រេងឥន្ធនៈ ឬឧស្ម័នឥន្ធនៈ
- បញ្ចូលក្បាលចំពួយប្រេងឥន្ធនៈទៅក្នុងធុងប្រេងឥន្ធនៈ ឬមួលក្បាលតឧស្ម័នឥន្ធនៈ របស់យានយន្ត ឱ្យបានត្រឹមត្រូវ និង
- កុំចាកចេញពីកន្លែងក្នុងអំឡុងពេលចាក់ប្រេងឥន្ធនៈ ឬឧស្ម័នឥន្ធនៈ។

គ- មុនពេលយានយន្តអតិថិជនចាកចេញ៖

- ដកចំពួយប្រេងឥន្ធនៈចេញពីធុងប្រេងឥន្ធនៈ ឬមួលក្បាលតឧស្ម័នឥន្ធនៈចេញពីយានយន្ត
- បិទគម្របធុងប្រេងឥន្ធនៈ ឬឧស្ម័នឥន្ធនៈយានយន្ត
- រៀបចំចំពួយ ក្បាលត និងទុយយោចាក់ប្រេងឥន្ធនៈ ឬឧស្ម័នឥន្ធនៈឱ្យបានត្រឹមត្រូវ និង
- ពិនិត្យសុវត្ថិភាព និងណែនាំឱ្យយានយន្តចេញ។

ឃ- ត្រូវរឹតបន្តឹងការចាក់ប្រេងឥន្ធនៈនិងឧស្ម័នឥន្ធនៈក្នុងបរិវេណស្ថានីយដូចខាងក្រោម៖

- ហាមចាក់ប្រេងសាំងចូលក្នុងប៊ីដុងជ័រ។ ប្រេងសាំងអាចចាក់ក្នុងធុងដែកដែលអាចប្រើជាមួយនឹងប្រេងសាំងបានត្រឹម ២០ លីត្រ
- ប្រេងម៉ាស៊ូតអនុញ្ញាតឱ្យបញ្ចូលក្នុងប៊ីដុងជ័រដែលជាប្រភេទសម្រាប់ប្រើជាមួយប្រេងម៉ាស៊ូតបានតែប៉ុណ្ណោះ និងមានចំណុះ ៣០ លីត្រ ឬតិចជាងនេះ។ ប្រេងម៉ាស៊ូតអាចចាក់បញ្ចូលក្នុងធុងចំណុះ ២០០ លីត្រ ឬតិចជាងនេះ

- ហាមចាក់ប្រេងសាំង និងប្រេងម៉ាស៊ូតបញ្ចូលដោយផ្ទាល់ពីពោងប្រេងឥន្ធនៈទៅប៊ីដុងជ័រ ឬធុង ឬរថយន្តស៊ីទែន និង
- ហាមបញ្ចូលឧស្ម័នឥន្ធនៈចូលធុង និង/ឬកំប៉ុងតាមក្បាលត ក្នុងស្ថានីយឧស្ម័នឥន្ធនៈ និងស្ថានីយរួមប្រេងឥន្ធនៈនិងឧស្ម័នឥន្ធនៈ។

ង-ត្រូវប្រុងប្រយ័ត្នអំពីគ្រោះថ្នាក់ដែលអាចកើតឡើងក្នុងពេលចាក់ប្រេងឥន្ធនៈ ឬឧស្ម័នឥន្ធនៈ ដូចខាងក្រោម៖

- ការចាក់ឱ្យហៀរកំពប់ចេញប្រេងឥន្ធនៈ ឬឧស្ម័នឥន្ធនៈ ដោយសារមិនមានប្រព័ន្ធបញ្ឈប់ដោយស្វ័យប្រវត្តិ ឬប្រព័ន្ធបញ្ឈប់ដោយស្វ័យប្រវត្តិមិនដំណើរការ
- ការបើក-បិទវ៉ាន ក្បាលតឧស្ម័នឥន្ធនៈមិនត្រឹមត្រូវ
- ការភ្ជាប់ និងការផ្ដាច់ក្បាលតឧស្ម័នឥន្ធនៈជាមួយធុងឧស្ម័នឥន្ធនៈយានយន្តដោយធ្វេសប្រហែស
- ការចាកចេញយានយន្តដោយមិនបានផ្ដាច់ចំពួយចាក់ប្រេងឥន្ធនៈ ឬក្បាលតឧស្ម័នឥន្ធនៈ និង
- ទុយយោធ្លាយ ឬចំពួយចាក់ប្រេងឥន្ធនៈ ឬក្បាលតឧស្ម័នឥន្ធនៈ និងទូចាក់ប្រេងឥន្ធនៈ ឬឧស្ម័នឥន្ធនៈខូច។

### ៣.៣-ការផ្ទេរប្រេងឥន្ធនៈឬឧស្ម័នឥន្ធនៈចេញពីរថយន្តស៊ីទែន

បុគ្គលិករបស់ស្ថានីយ និងអ្នកបើកបររថយន្តស៊ីទែនប្រេងឥន្ធនៈ ឬឧស្ម័នឥន្ធនៈត្រូវសហការគ្នាឱ្យបានល្អ ដើម្បីជានាសុវត្ថិភាពនៅពេលផ្ទេរប្រេងឥន្ធនៈ ឬឧស្ម័នឥន្ធនៈ ដោយត្រូវអនុវត្តការងារតាមជំហានដូចខាងក្រោម៖

ក-ពេលរថយន្តស៊ីទែនចូល៖

- ណែនាំរថយន្តស៊ីទែនឱ្យចូលចតចំទីតាំងផ្ទេរប្រេងឥន្ធនៈ ឬឧស្ម័នឥន្ធនៈឱ្យបានត្រឹមត្រូវ
- ដាក់កំណល់កល់កង់រថយន្តស៊ីទែន
- រក្សាអតិថិជនឱ្យនៅឆ្ងាយ
- រៀបចំឧបករណ៍ពន្លត់អគ្គិភ័យឱ្យនៅក្បែរ និងនៅខាងលើខ្យល់ និង
- តភ្ជាប់ខ្សែម៉ាសដីពីរថយន្តស៊ីទែនទៅបង្គោលខ្សែម៉ាសដី។

ខ-ពេលផ្ទេរប្រេងឥន្ធនៈ ឬឧស្ម័នឥន្ធនៈ

- ត្រូវបញ្ជាក់គ្នាទៅវិញទៅមកពីប្រភេទនិងបរិមាណប្រេងឥន្ធនៈ ឬឧស្ម័នឥន្ធនៈ លើបណ្ណដឹកជញ្ជូន និងបរិមាណដែលមានស្រាប់ក្នុងពោងនីមួយៗ
- កំណត់លំដាប់នៃការផ្ទេរប្រេងឥន្ធនៈតាមប្រភេទ
- ពិនិត្យទុយយោផ្ទេរប្រេងឥន្ធនៈ ឬឧស្ម័នឥន្ធនៈរបស់រថយន្តស៊ីទែន ក្រែងមានសេសសល់ប្រេងឥន្ធនៈ ឬឧស្ម័នឥន្ធនៈ
- ពិនិត្យកបំពង់ទទួលប្រេងឥន្ធនៈ និងភ្ជាប់ទុយយោឱ្យត្រូវតាមប្រភេទប្រេងឥន្ធនៈ ដោយមានក្បាលតំណត្រឹមត្រូវ
- ពិនិត្យកបំពង់ទទួលឧស្ម័នឥន្ធនៈ និងភ្ជាប់ទុយយោដោយមានក្បាលតត្រឹមត្រូវ
- ភ្ជាប់ទុយយោប្រមូលចំហាយប្រេងឥន្ធនៈ ឬទុយយោបឺតឧស្ម័នឥន្ធនៈត្រឡប់វិញ

- ត្រូវត្រួតពិនិត្យសុវត្ថិភាពអំឡុងពេលផ្ទេរប្រេងឥន្ធនៈ ឬឧស្ម័នឥន្ធនៈ ដោយតាមដាននាឡិកាចំណុះ (ចំពោះឧស្ម័នឥន្ធនៈ) និងការលេចធ្លាយផ្សេងៗនៅតាមតំណភ្ជាប់ និងទុយយោផ្ទេរ
- ពិនិត្យមើលបរិមាណប្រេងឥន្ធនៈ ឬឧស្ម័នឥន្ធនៈក្នុងពោងដែលបានផ្ទេរចូល និង
- បន្ទាប់ពីបញ្ជាក់បរិមាណរួចចុះហត្ថលេខាលើបង្កាន់ដៃផ្ទេរទទួលប្រេងឥន្ធនៈឬឧស្ម័នឥន្ធនៈ។

គ- ក្រោយពេលផ្ទេរប្រេងឥន្ធនៈ ឬឧស្ម័នឥន្ធនៈ

- ពិនិត្យមើលប្រេងឥន្ធនៈ ឬឧស្ម័នឥន្ធនៈដែលនៅសល់ក្នុងទុយយោផ្ទេរ និង
- ដកខ្សែម៉ាសដី ទុយយោផ្ទេរ ទុយយោប្រមូលចំហាយ ដាក់បំពង់ពន្លត់អគ្គិភ័យទៅកន្លែងដើមវិញ ដកកំណល់ពីកង់រថយន្តស៊ីទែន និងណែនាំរថយន្តស៊ីទែនឱ្យចាកចេញ។

### ៣.៤- ការរៀបរយទីធ្លា ការសម្អាត និងឯកសណ្ឋាន

ប្រធានគ្រប់គ្រងស្ថានីយ ត្រូវណែនាំបុគ្គលិកឱ្យអនុវត្តការងារនៅក្នុងស្ថានីយដូចខាងក្រោម៖

- មិនត្រូវដាក់វត្ថុឬឧបករណ៍ដែលងាយឆេះជិតគ្រឿងបង្ហុំស្ថានីយ
- មិនត្រូវដាក់វត្ថុ និងសម្ភារៈផ្សេងៗដែលជាឧបសគ្គដល់ផ្លូវយានយន្តចេញចូល និងធ្វើឱ្យចង្អៀតទីធ្លាស្ថានីយ
- ត្រូវរក្សាទុកឧបករណ៍ចាំបាច់ឱ្យមាននៅនឹងកន្លែងសម្រាប់ប្រើប្រាស់
- ត្រូវកំណត់ដែនចេញ-ចូលរបស់អ្នកមិនមែនអតិថិជន
- ត្រូវសម្អាត បន្ទប់ការិយាល័យ ហាងលក់ទំនិញ អគារប្តូរប្រេងរំអិល បន្ទប់ទឹក ទីតាំងពោងទូចាក់ ខឿនទូចាក់ ទុយយោចាក់ ចំពួយចាក់ ឬក្បាលត និងកបំពង់ទទួលប្រេងឥន្ធនៈ និងឧស្ម័នឥន្ធនៈជាដើម
- ត្រូវឱ្យបុគ្គលិកស្លៀកពាក់ឯកសណ្ឋានឱ្យបានត្រឹមត្រូវ និង
- ត្រូវមានធុងសំរាម។

### ៣.៥- ការឆ្លើយតបពេលមានអាសន្ន

ប្រធានគ្រប់គ្រងស្ថានីយ ត្រូវរៀបចំឱ្យមានលេខទូរស័ព្ទរបស់អង្គភាពនគរបាលបង្ការ ពន្លត់អគ្គិភ័យ និងសង្គ្រោះ ដែលនៅជិតទីតាំងស្ថានីយបិទនៅក្នុងការិយាល័យ សម្រាប់ហៅបន្ទាន់ពេលមានគ្រោះអគ្គិភ័យ។

វិធានការឆ្លើយតបបន្ទាន់ នៅពេលដែលមានការលេចធ្លាយប្រេងឥន្ធនៈឬឧស្ម័នឥន្ធនៈកើតឡើងរួមមាន៖

ក- ករណីលេចធ្លាយប្រេងឥន្ធនៈ ឬឧស្ម័នឥន្ធនៈទ្រង់ទ្រាយតូច

- ត្រូវប្រញាប់បិទវ៉ាន់ផ្នែកខាងដើមនៃកន្លែងដែលលេចធ្លាយនោះ
- ត្រូវផ្តល់ព័ត៌មានអំពីការលេចធ្លាយនោះទៅអ្នកពាក់ព័ន្ធជាបន្ទាន់
- ត្រូវហាមឃាត់ការធ្វើចរាចររបស់យានយន្តចូលក្នុងស្ថានីយ
- ត្រូវប្រយ័ត្នពីប្រភពបញ្ឆេះ និង
- នៅពេលដែលប្រេងឥន្ធនៈ ឬឧស្ម័នឥន្ធនៈបានលេចធ្លាយ ហើយត្រូវបានឆេះ ត្រូវបញ្ឈប់ការលេចធ្លាយ និងត្រូវប្រើបំពង់ពន្លត់អគ្គិភ័យប្រភេទពពុះសាប៊ូ ឬបំពង់ពន្លត់អគ្គិភ័យប្រភេទម្សៅ ឬបំពង់ពន្លត់អគ្គិភ័យប្រភេទឧស្ម័នកាបូនិក ដោយមិនត្រូវប្រើទឹកពន្លត់ទេ។

ខ- ករណីលេចធ្លាយប្រេងឥន្ធនៈ ឬឧស្ម័នឥន្ធនៈ ជាទ្រង់ទ្រាយធំ និងបង្កឱ្យមានការផ្ទុះឆេះ

- ត្រូវបិទគន្លឹះអាសន្ននិងជម្លៀសអតិថិជនចេញមកក្រៅជាបន្ទាន់
- បុគ្គលិកស្ថានីយត្រូវខិតខំពន្លត់អគ្គិភ័យដោយប្រើគ្រប់មធ្យោបាយដែលមាន
- ត្រូវរាយការណ៍ភ្លាមៗទៅអង្គភាពនគរបាលបង្ការ ពន្លត់អគ្គិភ័យ និងសង្គ្រោះ និង
- បន្ទាប់មកបុគ្គលិកទាំងអស់ត្រូវភៀសខ្លួនចេញពីកន្លែងកើតហេតុ ប្រសិនបើការពន្លត់អគ្គិភ័យដំណាក់កាលដំបូងមិនទទួលបានជោគជ័យ។